**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០១ ផក**

# ផែនការ

## ស្តីពី

## យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥

## រយៈពេល ០១ឆ្នាំ (ចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០)

ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ត្រូវបានដាក់ចេញឲ្យអនុវត្តជាបន្តបន្ទាប់ចំនួនបួនលើករួចមកហើយ ដោយប្រមូលផ្តុំកម្លាំងសរុប មធ្យោបាយសរុប បង្កើតបានជាចលនាជាតិមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀននៅកម្ពុជា ព្រមទាំងទទួលបាននូវការគាំទ្រ និងកោតសរសើរពីសំណាក់មជ្ឈដ្ឋានជាតិ អន្តរជាតិ ចំពោះស្មារតីទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល លើជោគវាសនាប្រទេសជាតិ និងប្រជាពលរដ្ឋផងដែរ។

តាមរយៈការចាត់តាំងអនុវត្តនូវវិធានការគន្លឹះទាំង៥ ដែលបានកំណត់ក្នុងផែនការយុទ្ធនាការ គួបផ្សំបទពិសោធន៍ដែលទទួលបានជាបន្តបន្ទាប់នាពេលកន្លងទៅ បានធ្វើឲ្យកិច្ចប្រតិបត្តិការក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនកាន់តែមានប្រសិទ្ធភាព។ ជាក់ស្តែង ក្នុងយុទ្ធនាការលើកទី៤កន្លងទៅ សមត្ថកិច្ចពាក់ព័ន្ធបានបើកប្រតិបត្តិការ បង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន ៩.៨០៦ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ២០.៤៩០នាក់ និងសារធាតុញៀនចាប់យកគ្រប់ប្រភេទសរុប ៧៥០,៧០គ.ក្រ រួមទាំងមធ្យោបាយសម្ភារ វត្ថុតាងមួយចំនួន។ ក្នុងនោះ សមត្ថកិច្ចបានបង្ក្រាបចាប់ខ្លួនមេខ្លោង និងកាត់ផ្តាច់ខ្សែរយៈបណ្តាញជួញដូរគ្រឿងញៀនធំៗ ចំនួន **៦១ករណី** ដោយបានចាប់ឃាត់ខ្លួនចំនួន **១៤០នាក់** យកមកផ្តន្ទាទោសតាមច្បាប់។

ការប្តេជ្ញាចិត្តលុបបំបាត់បទល្មើសគ្រឿងញៀននៅតាមក្លឹបកម្សាន្តឲ្យអស់នាឆ្នាំ២០១៩ ដោយគណៈបញ្ជាការដឹកនាំយុទ្ធនាការ និងតាមរយៈការជំរុញអនុវត្តវិធានការរដ្ឋបាល ទន្ទឹមនឹងវិធានការច្បាប់យ៉ាងតឹងរឹង កងកម្លាំងអនុវត្តច្បាប់ បានស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រឿងញៀនក្នុងទីតាំងក្លឹបកម្សាន្តចំនួន **១២ទីតាំង** (បិទជាស្ថាពរ ០៧ទីតាំង) ដែលប្រតិបត្តិការនេះ បានជះឥទ្ធិពលដល់ការបង្រួមទីផ្សារជួញដូរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅក្នុងប្រទេសផង និងជះឥទ្ធិពលជាវិជ្ជមាន ធ្វើឲ្យប្រភេទបទល្មើសព្រហ្មទណ្ឌមួយចំនួនដូចជា ប្លន់ប្រដាប់អាវុធ រំលោភសម្លាប់ ឆក់តាមទីសាធារណៈមានការថយចុះផងដែរ។ លទ្ធផលទាំងអស់នេះ គឺជាសក្ខីភាពឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់កងកម្លាំងអនុវត្តច្បាប់ដែលពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ក្រោមការចង្អុលដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់គណៈបញ្ជាការដឹកនាំយុទ្ធនាការ ដែលបានធ្វើឲ្យបរិយាកាសសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម កាន់តែមានភាពល្អប្រសើរឡើង។

ការបង្ក្រាបចាប់ខ្លួនមេខ្លោង និងខ្សែរយៈបណ្តាញករណីជួញដូរគ្រឿងញៀនធំៗ បានបង្ហាញឲ្យឃើញអំពីសមត្ថភាព បទពិសោធន៍របស់កងកម្លាំងអនុវត្តច្បាប់ក្នុងការរួមចំណែកទប់ស្កាត់ការនាំចូលឆ្លងកាត់ទៅក្រៅប្រទេសផង និងកាត់បន្ថយហានិភ័យ នៃការប្រើប្រាស់នៅក្នុងប្រទេសផងដែរ។ ទន្ទឹមនេះ ការឃាត់ខ្លួនជនសង្ស័យពាក់ព័ន្ធបទល្មើសគ្រឿងញៀន និងការបន្សាបព្យាបាលអ្នកប្រើប្រាស់សារធាតុញៀន បានកាត់បន្ថយក្តីបារម្ភរបស់ប្រជាពលរដ្ឋអំពីបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងមូលដ្ឋាន ក៏ដូចជាជួយស្រោចស្រង់អនាគតយុវវ័យ និងបង្កើនភាពកក់ក្តៅដល់អាណាព្យាបាល ឬក្រុមគ្រួសាររបស់ពួកគេផងដែរ។

អាស្រ័យដោយនិន្នាការនៃការផលិត ការចរាចរ និងការជួញដូរគ្រឿងញៀនខុសច្បាប់នៅក្នុងតំបន់ និងលើពិភពលោក នៅតែមានកំណើន និងនៅតែបន្តជះឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ដល់កម្ពុជា ជាពិសេសការលេចចេញនូវរូបភាព និងទ្រង់ទ្រាយថ្មីៗ នៃការលួចនាំចូលសារធាតុញៀនមកកម្ពុជា ដូចជាកំណើននៃការនាំចូលតាមព្រំដែន ព្រលានយន្តហោះ និងតាមបញ្ញើប្រៃសណីយ៍ ដែលសកម្មភាពទាំងនេះ ទាមទារឲ្យមានវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបឲ្យកាន់តែសកម្ម និងក្តៅគគុកបន្ថែមទៀត។ ស្ថិតក្នុងបរិបទនេះ រាជរដ្ឋាភិបាលសម្រេចបន្តដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ **លើកទី៥ រយៈពេល ០១ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ០១ ខែមករា រហូតដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០** ដូចខាងក្រោម ៖

## I. គោលការណ៍រួម

- បន្តចាត់តាំងអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពនូវបទបញ្ជាលេខ ០១ ប.ប ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ចាត់តាំងអនុវត្តយុទ្ធនាការលើកទី៥ ដោយផ្អែកតាមគោលការណ៍រួម និងវិធានការទាំង៥ ដែលបានកំណត់ក្នុងផែនការយុទ្ធនាការ និងគ្រប់វិធានការនៃយុទ្ធនាការលើកទី៤

- ពិនិត្យកែសម្រួលឡើងវិញ នូវសមាសភាពមួយចំនួននៅក្នុងយន្តការនៃយុទ្ធនាការលើកទី៤ ដើម្បីប្រើប្រាស់ជាយន្តការសម្រាប់អនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥។

## II. វិធានការ

បន្តជំរុញការអនុវត្តវិធានការទាំង ៥ ដែលមានចែងក្នុងផែនការយុទ្ធនាការលើកទី៤ ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត គួបផ្សំនឹងវិធានការជំនាញនានា ដើម្បីធ្វើជាមូលដ្ឋានចាត់តាំងអនុវត្ត ដោយត្រូវខិតខំធ្វើឲ្យបានសម្រេចនូវការងារសេសសល់ក្នុងយុទ្ធនាការលើកទី៤ និងត្រូវបន្តប្រមូលផ្តុំយកចិត្តទុកដាក់លើការងារជាអាទិភាពដូចតទៅ ៖

១. បង្កើនសកម្មភាពផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋទូទៅ ដោយត្រូវធ្វើបច្ចុប្បន្នភាពវិធីសាស្ត្រក្នុងការផ្សព្វផ្សាយអប់រំ ក្នុងនោះត្រូវបន្តយកចិត្តទុកដាក់ផ្តោតលើការបណ្តុះបណ្តាលជនបង្គោលទាំងនៅតាមក្រសួង ស្ថាប័ន អង្គភាព និងវិស័យឯកជននានា ដើម្បីរួមចំណែកដល់ការអប់រំឲ្យបានទូលំទូលាយ ស៊ីជម្រៅ ចំគោលដៅ និងមុខសញ្ញាងាយរងគ្រោះ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីច្បាប់ ក៏ដូចជាគ្រោះថ្នាក់ និងផលអវិជ្ជមានដែលបណ្តាលមកពីគ្រឿងញៀន ព្រមទាំងធ្វើការអំពាវនាវដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ គ្រប់មជ្ឈដ្ឋាន ឲ្យសកម្មចូលរួមក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សំដៅកាត់បន្ថយបទល្មើសគ្រឿងញៀន និងការពារសុខុមាលភាពសង្គម។

២. ត្រូវខិតខំរៀបចំឲ្យបាននូវវេទិកាជួបជាមួយវិស័យឯកជន និងសប្បុរសជន ជាពិសេសម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មដែលងាយរងហានីភ័យដោយសារបទល្មើសគ្រឿងញៀន រួមទាំងសិល្បករ សិល្បការិនី បណ្តាញសារព័ត៌មាន អ្នកដឹកនាំសាសនា អង្គការ-សង្គមស៊ីវិលនៅគ្រប់រាជធានី ខេត្ត រហូតដល់មូលដ្ឋាន សំដៅប្រមូលផ្តុំឲ្យមានការចូលរួមសហការគាំទ្រទាំងសកម្មភាព និងមូលនិធិ ក្នុងចលនាជាតិប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន។

៣. ជំរុញសកម្មភាពស្រាវជ្រាវ ស៊ើបអង្កេត និងបង្ការ ទប់ស្កាត់ បង្ក្រាបឲ្យបាននូវការនាំចូល ឆ្លងកាត់ ជួញដូរ និងប្រើប្រាស់តាមគោលដៅដែលងាយទទួលរងហានីភ័យ ឬកើតមានការជួញដូរ ការប្រើប្រាស់គ្រឿងញៀន ជាពិសេសតាមក្លឹបកម្សាន្ត ព្រមទាំងទីតាំងលួចលាក់ កែច្នៃផលិតសារធាតុញៀន ដោយត្រូវ៖

-ពង្រឹងការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ឲ្យដើរទន្ទឹមគ្នា និងអនុវត្តឲ្យបានម៉ឺងម៉ាត់ គ្មានការយោគយល់ និងលើកលែង សំដៅបង្រួមទីផ្សារជួញដូរ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ជាពិសេសត្រូវដកស្រង់បទពិសោធន៍ដែលបានអនុវត្តក្នុងប្រតិបត្តិការនៅប៉ូលិសចរណ៍ទាំង០៣ (ភ្នំពេញ សៀមរាប ព្រះសីហនុ) នាពេលកន្លងមក ដោយកំណត់ឲ្យបានជាក់លាក់នូវភូមិសាស្ត្រ និងគោលដៅអាទិភាព រៀបចំកម្មវិធីការងារជាក់ស្តែងសម្រាប់អនុវត្តកិច្ចការនេះច្បាស់លាស់ជាប់ជាប្រចាំ ដូចភ្លៀងរលឹម។

-ចំពោះបណ្តាខេត្តជាប់ព្រំដែន ត្រូវខិតខំចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនចេញ-ចូលឆ្លងកាត់ព្រំដែនទៅវិញទៅមកជាមួយប្រទេសជិតខាង ព្រមទាំងត្រូវខិតខំកសាងឲ្យបាននូវភូមិ-ឃុំ សង្កាត់ សគ្មានគ្រឿងញៀន ជាពិសេសត្រូវខិតខំពង្រីកវិសាលភាពបន្ថែមទៀត នៅតាមបណ្តាខេត្តជាប់ព្រំដែននៅភូមិភាគឦសាន។

-ខិតខំលើកកម្ពស់សមត្ថភាពក្នុងការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រឿងញៀនឲ្យដល់ឫសគល់ និងតស៊ូស្វែងរកឲ្យឃើញទីតាំងលួចលាក់កែច្នៃ ផលិតសារធាតុញៀននៅក្នុងប្រទេស។

៤. ពន្លឿនរាល់នីតិវិធីក្នុងការចាត់ចែងវត្ថុតាង និងទ្រព្យសម្បត្តិនានាពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលត្រូវបានរឹបអូស និងបង្កក ដើម្បីយកមកគាំទ្រក្នុងសកម្មភាពប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ព្រមទាំងត្រូវខិតខំឲ្យអស់ពីសមត្ថភាព ក្នុងការស្រាវជ្រាវ ស៊ើបអង្កេត និងរឹបអូសនូវហិរញ្ញប្បទានពាក់ព័ន្ធបទល្មើសគ្រឿងញៀន សំដៅរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

៥. លើកកម្ពស់សកម្មភាព កិច្ចសហប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ជាពិសេសបន្តខិតខំទប់ស្កាត់ការនាំចូលពីក្រៅប្រទេស និងស្រាវជ្រាវនូវបណ្តាញខ្សែរយៈឧក្រិដ្ឋជនជួញដូរគ្រឿងញៀនធំៗ ដើម្បីបង្ក្រាបឲ្យដល់ឫសគល់ ព្រមជាមួយនឹងការយកចិត្តទុកដាក់ក្នុងការប៉ះប៉ន់ និងលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅធ្វើឲ្យប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់ កាន់តែមានប្រសិទ្ធភាពខ្ពស់។

៦. បន្តពង្រឹង និងជំរុញសកម្មភាពអនុវត្តវិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម ដោយត្រូវមានយន្តការដឹកនាំ និងសម្របសម្រួលច្បាស់លាស់នៅថ្នាក់ឃុំ សង្កាត់ ជាមួយគ្នានេះ ត្រូវខិតខំលើកកម្ពស់សមត្ថភាព គុណភាព និងពង្រីកសេវាបន្សាបព្យាបាលដោយផ្អែកលើសហគមន៍ នៅតាមឃុំ-សង្កាត់គោលដៅអាទិភាព ឈានទៅពង្រីកវិសាលភាពគ្របដណ្តប់បានឃុំសង្កាត់នៅទូទាំងប្រទេស និងត្រូវជំរុញការងារសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ឲ្យបានរួចរាល់ ព្រមទាំងបន្តកសាងមណ្ឌលបណ្តោះអាសន្នសម្រាប់ព្យាបាល និងស្តារនីតិសម្បទាតាមរាជធានី ខេត្ត ដែលមានអំណោយផល។

៧. កសាងឲ្យបាននូវយន្តការតាមដាន ត្រួតពិនិត្យមុខសញ្ញាប្រើប្រាស់សារធាតុញៀន មុខសញ្ញាដែលបានសមាហរណកម្មចូលក្នុងសហគមន៍ ដើម្បីគ្រប់គ្រង និងមានវិធានការក្នុងការបង្ការ ទប់ស្កាត់មិនឲ្យពួកគេវិលត្រឡប់មកប្រើប្រាស់សារធាតុញៀនវិញ។

III. **ការចាត់តាំងអនុវត្ត**

១. គណៈបញ្ជាការដឹកនាំយុទ្ធនាការលើកទី៥ នេះគឺ ៖

- **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាប្រធានយុទ្ធនាការ**

- **ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ជាអនុប្រធានយុទ្ធនាការ**

- ប្រគល់ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលដឹកនាំផ្ទាល់លើការងារផ្សព្វផ្សាយអប់រំ និងការងារព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព្រមទាំងរៀបចំភូមិ ឃុំ សង្កាត់ ស គ្មានគ្រឿងញៀន នៅទូទាំងប្រទេស ដោយប្រើប្រាស់យន្តការអនុវត្តគោលនយោបាយ **«ភូមិ-ឃុំមានសុវត្ថិភាព»** ធ្វើជាយន្តការស្នូល

- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញនូវយន្តការអនុវត្ត ឲ្យស្របតាមស្មារតីនៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី**៥**។

២. ផ្អែកលើផែនការនេះ គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី**៥** យន្តការចំណុះទាំងអស់ រួមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវកសាងផែនការជាក់ស្តែង សម្រាប់ចូលរួមអនុវត្តតាមតួនាទី ភារកិច្ចរៀងៗខ្លួន។

៣. ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន ព្រមទាំងអនុវត្តវិន័យ និងអនុវត្តវិធានការច្បាប់មឺងម៉ាត់ចំពោះមន្ត្រីដែលមានជាប់ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈអភិបាលរាជធានី ខេត្តទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់៕

ថ្ងៃ សុក្រ ៥ រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**